មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា
អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ និង មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

# សេចក្ដីថ្លែងការណ៍រួម

# ការបំពានលើសិទ្ធិអ្នកឃ្លាំមើលសិទ្ធិមនុស្សនិងការបង្ក្រាបអ្នកតវ៉ាបង្ហាញពីការរំលោភលើសេរីភាពបញ្ចេញមតនៅតែបន្តក្នុងសង្គមកម្ពុជា

ភ្នំពេញ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០

យើងជាក្រុមអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះខាងលើនេះ សូមសំដែងនូវក្ដីព្រួយបារម្ភរបស់ខ្លួនយ៉ាងខ្លាំងចំពោះការរារាំងរបស់ប៉ូលីសខណ្ឌដង្កោទៅលើការតវ៉ារបស់ប្រជាពលរដ្ឋដែល ប្រឆាំងនឹងការរំលោភយកដីរបស់ពួកគាត់ ការចាប់ខ្លួន និងការវាយការណ៍ចំពោះប្រជាពលរដ្ឋណាដែលប៉ុនប៉ងចូលរួមធ្វើបាតុកម្មនេះ ព្រមទាំងការលុបរូបភាពដែលថតដោយអ្នកឃ្លាំមើលសិទ្ធិមនុស្ស មកពីសមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា និង អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ។

ការប៉ុនប៉ងធ្វើបាតុកម្មនេះធ្វើឡើងដើម្បីប្រឆាំងនឹងអ្នកដែលនៅពីក្រោយពីរឿងជំលោះដីធ្លី។ នៅថ្ងៃទី១ ខែមិនា ឆ្នាំ២០១០ ប្រជាពលរដ្ឋមកពីភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលពាក់ព័ន្ធនឹងរឿងទំនាស់ដីធ្លីជាមួយនឹងលោក អ៊ិន សាម៉ុនជាអគ្គលេខាធិការរង ក្រសួងមហាផ្ទៃ មានបំណងធ្វើបាតុកម្មតវ៉ាដើម្បីឲ្យមានអន្តរាគមន៍លើករណីនេះនៅគេហដ្ឋាននាយករដ្ឋមន្ត្រីហ៊ុនសែន នៅក្រុងតាខ្មៅ។ ប៉ុន្តែនៅវេលាម៉ោង៨ព្រឹក ប្រជាពលរដ្ឋទាំងនោះត្រូវ ប៉ូលីសប្រដាប់ដោយខែលនិងដំបងឆក់រារាំង និងស្កាត់មិនឲ្យពួកគាត់ធ្វើដំណើរទៅមុខទៀត។ បន្ទាប់ពីការប្រឈមមុខជាមួយប្រជាពលរដ្ឋ ប៉ូលីសបានចាប់ខ្លួនប្រជាពលរដ្ឋ៨នាក់ ហើយម្នាក់ក្នុងចំណោមពួកគាត់បានអះអាងថាការចាប់ខ្លួននេះមិនបានបញ្ជាក់ពីហេតុផលណាមួយឡើយ។ ជាងនេះទៅទៀត ក្រុមប៉ូលីសទាំងនោះបានដកហូតម៉ាស៊ីនថតពីសកម្មជនឃ្លាំមើលសិទ្ធិមនុស្សមកពីអង្គការលីកាដូ និងអាដហុក ព្រមទាំងបានលុបរូបភាពទាំងអស់នៅក្នុងម៉ាស៊ីនថតរបស់ពួកគាត់ដែលបានថតយកព្រឹត្តិការណ៍ខាងលើនេះ។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ មានសេចក្ដីរាយការណ៍ថា ប្រជាពលរដ្ឋចំនួន៧នាក់ ក្នុងចំណោមអ្នកដែលត្រូវចាប់ខ្លួនត្រូវបានដោះលែង បន្ទាប់ពីពួកគាត់ត្រូវប៉ូលីសគុកព្រៃសបានគំរាមឲ្យផ្ដិតមេដៃយល់ព្រមបញ្ឈប់ធ្វើការតវ៉ាទាមទារដីរបស់ពួកគាត់។ យោងតាមកាសែតភ្នំពេញប៉ុស្ដិ៍បានឲ្យ

ដឹងថា ប៉ូលីសបានប្រាប់ក្រុមគ្រួសាររបស់ជនរងគ្រោះខាងលើនេះថាគាត់នឹងត្រូវដោះលែង "លុះត្រាតែគាត់យល់ព្រមសារភាពទទួលកំហុសរបស់គាត់"។ បន្ទាប់មកគាត់ត្រូវដោះលែងនៅថ្ងៃទី២មិនាបន្ទាប់ពីនាងយល់ព្រមដកខ្លួនក្នុងការតវ៉ាលើរឿងដីធ្លីនេះ។

ចំពោះបញ្ហានេះ យើងសំដែងនូវសេចក្តីព្រួយបារម្ភដូចខាងក្រោមនេះ៖

- ទី១ ការរារាំងមិនឲ្យប្រជាពលរដ្ឋធ្វើបាតុកម្មតវ៉ាខាងលើនេះ អាជ្ញាធរប៉ូលីសទាំងនោះ បានរំលោភទៅលើសេរីភាពបញ្ចេញមតិនិងការជួបប្រជុំរបស់ប្រជាពលរដ្ឋដែលបានធានានៅក្នុងមាត្រា៤១នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការស្វែងរកជំនួយពីអ្នកតំណាងរាស្ត្ររបស់ពួកគាត់ដែលបានជ្រើសរើសតាមគោលការណ៍ប្រជាធិបតេយ្យ។
- ទី២ ការចាប់ឃុំខ្លួនប្រជាពលរដ្ឋទាំង៨រូបខាងលើ ដោយមិនបានបញ្ជាក់អំពីហេតុផល ដែលពួកគាត់ត្រូវចាប់ខ្លួននោះ ប៉ូលីសមានសមត្ថកិច្ច បានរំលោភទៅលើមាត្រាទី៩៧ នៃក្រមនិតិវិធីព្រហ្មទណ្ឌដែលចែងថា "កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអោយដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះដោយប្រាប់អោយបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ" ហើយ មាត្រា៩ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយបានចែងថា "បុគ្គលណាម្នាក់ដែលត្រូវចាប់ខ្លួនត្រូវតែមានការបញ្ជាក់អំពីមូលហេតុនៃការចាប់ខ្លួននោះ។ ចំណែកមាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាក៏ចែងអំពីចំណុចនេះដែរ។
- ទី៣ រាល់ការគំរាមប្រជាពលរដ្ឋដាក់គុក ក្នុងករណីដែលពួកគាត់មិនបោះបង់ការទាមទារសិទ្ធិលើដីនោះ អាជ្ញាធរដែលមិនបានយកបញ្ហាវិវាទទាំងនោះមកដោះស្រាយ វាគឺជាកំហុសរបស់អាជ្ញាធរ និងជាការរំលោភទៅលើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។
- ទី៤ ការលុបរូបភាពដែលថតដោយស្របច្បាប់របស់អ្នកឃ្លាំមើលសិទ្ធិមនុស្សនៅក្នុងទីសាធារណៈ មន្ត្រីប៉ូលីសខាងលើបានរំលោភទៅលើសេរីភាពបញ្ចេញមតិរបស់ពួកគាត់ និងរំលោភទៅលើតួនាទីរបស់អ្នកឃ្លាំមើលសិទ្ធិមនុស្ស នៅក្នុងសង្គមប្រជាធិបតេយ្យ។

ដើម្បីបញ្ឈប់នូវក្តីព្រួយបារម្ភខាងលើនេះ យើងជាក្រុមអង្គការក្រៅរដ្ឋាភិបាល សូមអំពាវនាវឲ្យមាន ការបញ្ឈប់ជាបន្ទាន់នូវការគំរាមកំហែងទៅលើប្រជាពលរដ្ឋដែលធ្វើការទាមទារលើករណីដីធ្លីនេះពីសំណាក់អាជ្ញាធរដែលពាក់ព័ន្ធនឹងករណីនេះ។ ជាងនេះទៅទៀត សូមយើងសូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាដាក់បញ្ជាទៅដល់រាល់មន្ត្រីប៉ូលីសទូទាំងប្រទេសឲ្យការពារនូវសេរីភាពបញ្ចេញមតិ និងការជួបប្រជុំចំពោះអ្នកដែលទទួលរងការរំលោភសិទ្ធិមនុស្ស និងសិទ្ធិបញ្ចេញមតិរបស់អ្នកឃ្លាំមើល

លើការរំលោភសិទ្ធិមនុស្ស ព្រមទាំងបញ្ឈប់រាល់សកម្មភាពទាំងឡាយដែលរារាំងដល់ការគោរពសិទ្ធិខាងលើនេះ ហើយផ្ទុយទៅនឹងអ្វីដែលបានចែងនៅក្នុងមាត្រា៤១ នៃច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។

ពត៌មានបន្ថែមសូមទាក់ទង៖


លោក អ៊ូ វីរៈ
ប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
ទូរស័ព្ទ ៖ +855 12 4040 51
Email: ouvirak@cchrcambodia.org

លោក នី ចរិយា
អ្នកសម្របសម្រួល សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
ទូរស័ព្ទ ៖ +855 11 274959
Email: nychakrya@yahoo.com

លោកស្រី Naly Pilorge
នាយក អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ (LICADHO)
ទូរស័ព្ទ ៖ +855 11 274959
Email: contact@licadho-cambodia.org

លោក យ៉េងវីរៈ
នាយកប្រតិបត្តិ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
ទូរស័ព្ទ ៖ +855 12 801235
Email: virakyeng@clec.org.kh